blue california

Promise Health Plan



# អត្ថប្រយោជន៍ Medi-Cal ដែលធានារ៉ាប់រងដោយគម្រោង Blue Shield of California Promise Health Plan

## កម្មវិធី Provisional Postpartum Care Extension Program

កម្មវិធី Provisional Postpartum Care Extension (PPCE) Program ផ្តល់ការធានារ៉ាប់រងបន្ថែមដល់សមាជិករបស់គម្រោង Medi-Cal ដែលមានស្ថានភាពសុខភាពផ្លូវចិត្តទាក់ទងនឹងភាពជាមាតា ក្នុងកំឡុងពេលមានគភ៌ ឬក្រោយមានគភ៌ ។

គម្រោង Blue Shield of California Promise Health Plan ធានារ៉ាប់រងលើការថែទាំសុខភាពផ្លូវចិត្តទាក់ទងនឹងភាពជាមាតា សម្រាប់ស្ត្រី នៅពេលមានគភ៌ និងរហូតដល់ទៅពីរខែក្រោយមានគភ៌ ។ កម្មវិធី PPCE ផ្តល់ជូនបន្ថែមនូវការធានារ៉ាប់រងនោះរហូតដល់ទៅ 12 ខែក្រោយការធ្វើរោគវិនិច្ឆ័យ ឬគិតចាប់ពី ការបញ្ចប់នៃការមានគភ៌, មួយណាក៏ដោយដែលកើតក្រោយ ។

ដើម្បីមានលក្ខណ:សម្បត្តិចូលរួមកម្មវិធ PPCE នេះ គ្រូពេទ្យរបស់អ្នកត្រូវតែបញ្ជាក់រោគវិនិច្ឆ័យរបស់អ្នកថាមានស្ថានភាពសុខភាពផ្លូវចិត្តទាក់ទងនឹងភាពជាមាតា ក្នុងរយ:ពេល 150 ថ្ងៃក្រោយការបញ្ចប់នៃការមានគភ៌ ។ សូមសួរគ្រូពេទ្យរបស់អ្នកអំពីសេវាទាំងនេះ បើសិនអ្នកគិតថាអ្នកត្រូវការវា ។ បើសិនគ្រូពេទ្យរបស់អ្នកគិតថា អ្នកគួរតែទទួលបានសេវាទាំងនេះពីកម្មវិធី PPCE នៅគ្រូពេទ្យរបស់អ្នកបំពេញ ហើយបញ្ជូនបែបបទមកឲ្យអ្នក ។